THE SCHOOL DISTRICT OF PHILADELPHIA

**EDUCATION CENTER**
440 North Broad Street
Philadelphia, PA 19130

ជូនចំពោះ ក្រុមគ្រួសារ ដៃគូ និងសហគមន៍ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

រដូវរងាកំពុងតែខិតចូលមកយ៉ាងឆាប់រហ័ស ហើយយើងទន្ទឹងរង់ចាំរដូវប្រកួតកីឡានារដូវរងាមួយទៀត ដើម្បីបង្ហាញពីការងារ និងទេពកោសល្យរបស់សិស្សដែលជាកីឡាករ និងគ្រូបង្វឹករបស់យើង។ នៅពេលដែលយើងបន្តផ្តល់អាទិភាពសុវត្ថិភាពដល់សិស្សដែលជាកីឡាករ ក្រុមគ្រួសារ និងអ្នកទស្សនារបស់យើង យើងចង់ចែករំលែកព័ត៌មានថ្មីៗអំពីគោលការណ៍ណែនាំសម្រាប់អ្នកទស្សនារបស់យើង ដែលអនុញ្ញាតឱ្យការប្រកួតរបស់យើងប្រព្រឹត្តទៅដោយសុវត្ថិភាព និងគ្មានការរំខាន។

ប្រតិបត្តិភ្លាមៗ ហើយសម្រាប់រយៈពេលនៃរដូវកាលកីឡារដូវរងា អ្នកទស្សនាណាដែលចូលរួមព្រឹត្តិការណ៍កីឡាវិទ្យាល័យរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា នៅអគាររបស់ក្រសួងអប់រំ ឬមិនមែនជាអគាររបស់ក្រសួងអប់រំ សង្ឃឹមថានឹងគោរពតាមគោលការណ៍ណែនាំដូចមានខាងក្រោមនេះ៖

1. អ្នកទស្សនាទាំងអស់ត្រូវតែគោរពតាមការត្រួតពិនិត្យសុវត្ថិភាពនៅក្នុងព្រឹត្តិការណ៍កីឡាទាំងអស់។
2. សិស្សបឋមសិក្សា ឬមធ្យមសិក្សាទាំងអស់ ត្រូវមានឪពុកម្តាយ ឬអាណាព្យាបាលមកជាមួយ។
3. មានតែសិស្សវិទ្យាល័យដែលគាំទ្រក្រុមរបស់ខ្លួន ឬក្រុមមកប្រកួតប៉ុណ្ណោះដែលនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងទីប្រកួត។ សិស្សមិនអាចទិញសំបុត្រចូលបានទេ លុះត្រាតែពួកគេបង្ហាញអត្តសញ្ញាណប័ណ្ណសិស្ស ហើយ**អាចចូលក្នុងទីប្រកួតបាន ប្រសិនបើពួកគេបង្ហាញទាំងសំបុត្រចូល និងអត្តសញ្ញាណប័ណ្ណសិស្ស នៅទីតាំងប្រកួត**។
4. ឪពុកម្តាយ អាណាព្យាបាល និងអ្នកទស្សនាពេញវ័យផ្សេងទៀតនឹងត្រូវបានអនុញ្ញាតឱ្យទិញសំបុត្រចូលនៅ តូប/តុ លក់សំបុត្រ នៅទីតាំងប្រកួត។ បើមិនទិញសំបុត្រចូល សម្រាប់ការប្រកួតដែលតម្រូវឱ្យទិញសំបុត្រ គេនឹងមិនអនុញ្ញាតឱ្យចូលទេ ដោយមិនគិតពីរយៈពេលដែលនៅសល់ក្នុងការប្រកួតនោះ។ ***គេនឹងមិនអនុញ្ញាតឱ្យអ្នកទស្សនាចូលក្នុងទីប្រកួតទេ ក្រោយពេលប្រកួតចប់ពាក់កណ្តាលហើយ។***
5. នៅពេលដែលអ្នកទស្សនាចាកចេញពីអាគារ ពួកគេនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលមកវិញទេ។
6. បុគ្គល ឬសកម្មភាពដែលគួរអោយសង្ស័យ ត្រូវរាយការណ៍ទៅបុគ្គលិករបស់ក្រសួងអប់រំ និងភ្នាក់ងារផ្នែកសុវត្ថិភាពនៅសាលារបស់ក្រសួងអប់រំជាបន្ទាន់។ យើងសូមរំលឹកដល់សហគមន៍របស់យើងថា ប្រសិនបើអ្នក «ឃើញអ្វីមួយគួរឱ្យសង្ស័យ - សូមនិយាយប្រាប់នូវអ្វីដែលបានឃើញនោះ»។
7. ក្រសួងអប់រំរក្សាសិទ្ធិក្នុងការបដិសេធការចូល និង/ឬ ដេញនរណាម្នាក់ចេញពីកន្លែងកីឡា សម្រាប់ការមិនគោរពតាមការណែនាំរបស់ក្រសួងអប់រំសម្រាប់អ្នកទស្សនា។
8. អ្នកទស្សនាត្រូវបានហាមឃាត់មិនឱ្យយករបស់របរដែលធំជាងកាបូបរបស់បុរស ឬកាបូបតូចរបស់ស្ត្រី។ ថង់ធំៗ កាបូបម្យ៉ាង បាល់ ប្រអប់ ។ល។ នឹងមិនត្រូវបានអនុញ្ញាតឱ្យយកមកក្នុងកីឡដ្ឋាន ឬកន្លែងប្រកួតទេ។
9. អ្នកទស្សនាត្រូវតែអង្គុយក្នុងកៅអី ឬកន្លែងអង្គុយដែលមានបន្ទះវែងៗសម្រាប់ព្រឹត្តិការណ៍កីឡា។ ហាមដើរត្រេតត្រត ឬឈរពាំងគេក្នុងអំឡុងពេលព្រឹត្តិការណ៍កីឡា។

THE SCHOOL DISTRICT OF PHILADELPHIA

**EDUCATION CENTER**
440 North Broad Street
Philadelphia, PA 19130

10. សាលារៀននីមួយៗអាចមានការណែនាំបន្ថែមសម្រាប់អ្នកទស្សនា យោងទៅលើចំនួនមនុស្សដែលអាចដាក់បាន និងប្លង់នៃកន្លែងប្រកួតរបស់ពួកគេ។ គេសុំឱ្យអ្នកទស្សនាទាក់ទងទៅសាលាមុនពេលចូលរួមក្នុងព្រឹត្តិការណ៍។

ជាថ្មីម្តងទៀត សុវត្ថិភាពរបស់សិស្ស និងបុគ្គលិករបស់យើង គឺជាអាទិភាពចម្បងរបស់យើង។ យើងសូមអរគុណចំពោះការខិតខំប្រឹងប្រែងរបស់អ្នកគ្រប់គ្នាក្នុងការប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំទាំងនេះ ដើម្បីឱ្យបទពិសោធន៍របស់អ្នកគាំទ្រកីឡាមានសុវត្ថិភាពជាបន្ត និងសប្បាយរីករាយសម្រាប់អ្នកគ្រប់គ្នាដែលមកទស្សនាកីឡដ្ឋានរបស់យើង។ សូមអរគុណចំពោះការបន្តក្នុងភាពជាដៃគូ និងការគាំទ្រដល់សិស្សរបស់យើង។

ដោយសេចក្តីស្មោះស្ម័គ្រ

Kevin J. Bethel
ប្រធានផ្នែកសុវត្ថិភាពសាលា
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា